01721126



**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-Mar-2023, 15:51
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្ដីសង្ខេបរបស់ ខៀវ សំផន បន្ទាប់ពីការផ្ទេរគាត់ទៅកាន់ពន្ធនាគារខេត្តកណ្ដាល**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Fergal GAYNOR
(បម្រុង)

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម C. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Phillip RAPOZA
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**
**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**
ពេជ្យ អង្គ
Falguni DEBNATH

**ជនជាប់ចោទ**
ខៀវ សំផន

**មេធាវីការពារក្ដី**
គង់ សំអុន
Anta GUISSÉ

# I. សេចក្តីផ្តើម

1. នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ ក្រុមមេធាវីការពារក្តី ខៀវ សំផន ("មេធាវីការពារក្តី") បានដាក់សេចក្តីសង្កេតបង្ហាញពីកង្វល់អំពី (១) ការលំបាករបស់គាត់ក្នុងការពិនិត្យមើលសាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២[1] ប្រសិនបើមិនប្រើកុំព្យូទ័រយួរដៃរបស់គាត់ ដែលការណ៍នេះបង្ហាញថាគេមិនអនុញ្ញាតឲ្យគាត់ប្រើនៅក្នុងពន្ធនាគារខេត្តកណ្តាល និង (២) គាត់គ្មានលទ្ធភាពទំនាក់ទំនងជាមួយមេធាវីអន្តរជាតិរបស់គាត់[2]។ មេធាវីការពារក្តីលើកឡើងថា បញ្ហាទាំងពីរនេះរារាំង ខៀវ សំផន មិនឲ្យទទួលបានការណែនាំសមស្រប និងបានផ្តល់សេចក្តីសង្កេតទាក់ទងនឹងលទ្ធភាពនៃការរៀបចំបណ្តឹងសើរើសាលក្រមស្ថាពរ អនុលោមតាមវិធាន ១១២ នៃវិធានផ្ទៃក្នុង[3]។ មេធាវីការពារក្តីក៏បានយោងសំអាងកាតព្វកិច្ចផ្នែកសីលធម៌ក្នុងការជួយ ខៀវ សំផន ស្វែងយល់អំពីសំអាងហេតុគាំទ្រសាលដីកានោះផងដែរ[4]។

2. លើសពីនេះទៀត មេធាវីការពារក្តីក៏បង្ហាញមន្ទិលអំពីស្ថាប័នសមស្របសម្រាប់ដោះស្រាយកង្វល់ទាំងនេះ ដោយចោទសួរថាតើ យោងតាមសេចក្តីសង្កេតរបស់ការិយាល័យរដ្ឋបាលនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣[5] អង្គជំនុំជម្រះតុលាការកំពូលនៅបន្តដំណើរការក្នុងទម្រង់បច្ចុប្បន្នរបស់ខ្លួនឬទេ និងថាតើអង្គជំនុំជម្រះនេះនៅតែមានយុត្តាធិការលើបញ្ហាទាក់ទងនឹងសិទ្ធិរបស់ ខៀវ សំផន ឬទេ[6]។

3. សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងសិទ្ធិរបស់ ខៀវ សំផន ក្នុងការអាន និងស្វែងយល់អំពីសាលដីកានោះទេ ប៉ុន្តែសង្កេតឃើញថា បណ្តឹងសើរើតាមវិធាន ១១២ នោះ គឺជាឧបាស្រ័យវិសាមញ្ញមួយដែលមិនពាក់ព័ន្ធជាចម្បងទៅនឹងការវិភាគសាលដីកាជាលម្អិត ឧទាហរណ៍ តាមវិធីមួយដែល

[1] ឯកសារ **F76** សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ("សាលដីកា")។

[2] ឯកសារ **F83** សេចក្តីសង្កេតបន្ទាប់ពីផ្ទេរលោក ខៀវ សំផន ទៅឃុំឃាំងនៅពន្ធនាគារខេត្តកណ្តាល និងចម្លើយតបរបស់រដ្ឋបាលតុលាការ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ (ជូនដំណឹងថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣) ("សេចក្តីសង្កេតរបស់មេធាវីការពារក្តី") កថាខណ្ឌ ៦-៩។

[3] ឯកសារ **F83** សេចក្តីសង្កេតរបស់មេធាវីការពារក្តី កថាខណ្ឌ ៩។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មទី ១០) ដែលបានកែប្រែនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ ("វិធានផ្ទៃក្នុង") វិធាន ១១២។

[4] ឯកសារ **F83** សេចក្តីសង្កេតរបស់មេធាវីការពារក្តី កថាខណ្ឌ ១០។

[5] ឯកសារ **F77/1/2** ចម្លើយតបរបស់ការិយាល័យរដ្ឋបាល ទៅនឹងសំណើរបស់អង្គជំនុំជម្រះ ស្នើសុំព័ត៌មានទាក់ទងនឹងការគ្រប់គ្រងការអនុវត្តទោសរបស់ ខៀវ សំផន ចុះថ្ងៃទី២៣ កុម្ភៈ ឆ្នាំ២០២៣ ("សេចក្តីសង្កេតរបស់ការិយាល័យរដ្ឋបាល")។

[6] ឯកសារ **F83** សេចក្តីសង្កេតរបស់មេធាវីការពារក្តី កថាខណ្ឌ ១៣-១៦។

បណ្ដឹងសាទុក្ខធម្មតាប្រឆាំងនឹងសាលក្រមនោះទេ។ សហព្រះរាជអាជ្ញាសង្កេតឃើញទៀតថា វាច្បាស់ណាស់ថា អង្គជំនុំជម្រះតុលាការកំពូលនៅតែដំណើរការ និងកំពុងតែចូលរួមយ៉ាងសកម្មក្នុងមុខងាររបស់ខ្លួន ដែលមានចែងក្នុងកិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ អាស្រ័យហេតុនេះ មិនមានមូលហេតុណាមួយក្នុងការសង្ស័យថាតើ អង្គជំនុំជម្រះនេះគឺជាវេទិការសមស្របសម្រាប់ដោះស្រាយការចោទប្រកាន់អំពីការរំលោភណាមួយលើសិទ្ធិរបស់ ខៀវ សំផន នោះទេ។

## II. ច្បាប់ជាធរមាន

4. វិធាន ១១២(១) ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

ទណ្ឌិត [...] អាចធ្វើបណ្ដឹងសើរើចំពោះសាលក្រមស្ថាពរ ឬសាលដីកាស្ថាពរ ទៅអង្គជំនុំជម្រះតុលាការកំពូលបាន កាលណាមានមូលហេតុដូចខាងក្រោម៖

ក- ភស្តុតាងថ្មីត្រូវបានរកឃើញដោយហេតុថា៖

(១) មិនមានភស្តុតាងនោះនៅពេលជម្រះក្ដី ហើយការដែលមិនអាចរកបាននៃភស្តុតាងនោះ មិនមែនជាកំហុសមួយផ្នែក ឬទាំងស្រុងរបស់ភាគីធ្វើពាក្យបណ្ដឹង។

(២) មានលក្ខណៈសំខាន់គ្រប់គ្រាន់ដែលថា បើផ្ដល់ភស្តុតាងនេះឲ្យក្នុងពេលជំនុំជម្រះ នោះនឹងនាំឲ្យសាលដីកាមានការប្រែប្រួល។

ខ- មានការរកឃើញថ្មីថា ភស្តុតាងដែលត្រូវបានជំនុំជម្រះ និង យកមកធ្វើជាមូលដ្ឋាននៃការផ្ដន្ទាទោសនោះ មានភាពក្លែងបន្លំ ឬ ខុសការពិត។

គ- មានចៅក្រមមួយរូប ឬ ច្រើនរូប ដែលចូលរួមក្នុងការស៊ើបសួរ ឬ ការផ្ដន្ទាទោសបានប្រព្រឹត្តខុសឆ្គង យ៉ាងធ្ងន់ធ្ងរនឹងក្រមសីលធម៌ ឬ បំពានលើតួនាទីក្នុងការស្វែងរកយុត្តិធម៌ ដែលអាចនាំឲ្យមានការបណ្ដេញចេញបាន តាមវិធានផ្ទៃក្នុងនេះ[7]។

## III. សេចក្ដីសន្និដ្ឋាន

### *i. ការប្រើកុំព្យូទ័រយួរដៃ និងជួបជាមួយមេធាវីជាតិ*

5. សហព្រះរាជអាជ្ញាធ្វើសេចក្ដីសង្កេតមួយចំនួនទាក់ទងនឹងអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធនឹង (ក) ការប្រើកុំព្យូទ័រយួរដៃ និង (ខ) ការរៀបចំឲ្យមាននីតិវិធីអនុញ្ញាតឲ្យមេធាវីជាតិរបស់គាត់គឺលោក គង់ សំអុន អាចទៅសួរសុខទុក្ខ ខៀវ សំផន ក្នុងលក្ខខណ្ឌល្អបំផុត។

---

[7] វិធាន ១១២(១) នៃវិធានផ្ទៃក្នុង។

6. ដូចដែលការិយាល័យរដ្ឋបាលបានកត់សម្គាល់យ៉ាងត្រឹមត្រូវថា "ទណ្ឌិត ខៀវ សំផន គឺស្ថិតក្រោមយុត្តាធិការទាំងស្រុងរបស់អគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ"[8]។ ដូចគ្នានឹងអ្នកទោសផ្សេងទៀតក្រោមយុត្តាធិការអគ្គនាយកដ្ឋានពន្ធនាគារ ខៀវ សំផន ត្រូវអនុវត្តតាមបទបញ្ជាពន្ធនាគារទាក់ទងនឹងការប្រើប្រាស់កុំព្យូទ័រយួរដៃ ឬឧបករណ៍អេឡិចត្រូនិកផ្សេងទៀត។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា ខៀវ សំផន មិនបានបង្ហាញសិទ្ធិជាទូទៅណាមួយនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលអនុញ្ញាតឱ្យអ្នកទោសប្រើកុំព្យូទ័រយួរដៃ ហើយក៏មិនបានបង្ហាញថានឹងមានហានិភ័យពិតប្រាកដដែលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីច្បាប់ ប្រសិនបើការប្រើប្រាស់នោះមិនត្រូវបានផ្តល់ឱ្យគាត់។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា ខៀវ សំផន ទទួលបានសាលដីកាបណ្តឹងសាទុក្ខ ដែលគាត់មានជាភាសាខ្មែរ បារាំង និងអង់គ្លេស។ មិនមានមូលហេតុណាដែលថាសាលដីកានេះ មិនអាចបោះពុម្ពឧទាហរណ៍ ក្នុងទម្រង់ទំហំ A3 ដើម្បីងាយស្រួលអាននោះឡើយ។ មេធាវីជាតិរបស់ ខៀវ សំផន អាចជួបជាមួយគាត់នៅពន្ធនាគារខេត្តកណ្តាល ផ្តល់ឯកសារឱ្យគាត់ និងពិភាក្សាសាលដីកានោះជាមួយគាត់[9]។ មេធាវីជាតិរបស់ ខៀវ សំផន និយាយភាសាខ្មែរ ដែលជាភាសាកំណើតរបស់ ខៀវ សំផន ហើយក៏ជាភាសាមួយដែលមានក្នុងសាលដីកា។ មេធាវីជាតិរបស់ ខៀវ សំផន ក៏អាចចូលមើលសម្ភារភស្តុតាងទាំងអស់ដែលយោងសំអាងនៅក្នុងសាលដីកា។ ដូច្នេះ ខៀវ សំផន មានមេធាវីដែលអាចទំនាក់ទំនាក់ជាមួយគាត់តាមរយៈភាសាដែលគាត់យល់ និងដែលអាចចូលមើលសម្ភារទាំងអស់ដែលត្រូវការដើម្បីស្វែងយល់ និងពន្យល់អំពីសាលដីកាបណ្តឹងសាទុក្ខនេះ។

7. ក្នុងបរិបទនេះ សហព្រះរាជអាជ្ញាកត់សម្គាល់ថា នៅពេលដែលពួកគាត់ទៅមើលពន្ធនាគារខេត្តកណ្តាល ក្នុងខែធ្នូ ឆ្នាំ២០២២ មុនពេលផ្ទេរ ខៀវ សំផន ពួកគាត់ទទួលបានការធានាថា ខៀវ សំផន ត្រូវបានអនុញ្ញាតឱ្យជួបអ្នកសួរសុខទុក្ខចាប់ពីម៉ោង ៨:០០-១១:០០ ព្រឹក និងពីម៉ោង ២:០០-៥:០០ ល្ងាច ប្រាំមួយថ្ងៃក្នុងមួយសប្តាហ៍ ហើយ មេធាវីរបស់គាត់ត្រូវបានអនុញ្ញាតឱ្យទៅសួរសុខទុក្ខគាត់ធ្វើការពិភាក្សាជាមួយគាត់ និងបង្ហាញឯកសារទៅកាន់គាត់ក្នុងអំឡុងម៉ោងទាំងនោះ[10]។ លើសពីនេះ បន្ទប់ដែលរៀបចំតាមតម្រូវការរបស់ ខៀវ សំផន មានទំហំធំល្មម និងផ្តល់កន្លែងសមស្របសម្រាប់គាត់ធ្វើការពិភាក្សាសម្ងាត់ នៅពេលជួបជាមួយមេធាវីជាតិរបស់គាត់។ ទីម្តប់នៅខាងក្រៅបន្ទប់

[8] ឯកសារ **F77/1/2** សេចក្តីសង្កេតរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ២។

[9] ឯកសារ **F83** សេចក្តីសង្កេតរបស់មេធាវីការពារក្តី កថាខណ្ឌ ១១។

[10] ឯកសារ **F81** សេចក្តីសង្កេតរបស់សហព្រះរាអាជ្ញាស្តីពីលក្ខខណ្ឌនៃការអនុវត្តទោស ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣ កថាខណ្ឌ ២៣។

របស់គាត់ ដែលសម្រាប់តែ ខៀវ សំផន ប្រើ ផ្តល់កន្លែងសមស្របបន្ថែមទៀតសម្រាប់ជំនួបជាមួយនឹងមេធាវីជាតិរបស់គាត់។

8. សហព្រះរាជអាជ្ញាកត់សម្គាល់ផងដែរថា ការិយាល័យរដ្ឋបាលបានចាត់មនុស្សពីរនាក់ ដែលមេធាវីការពារក្តីអាចសុំជំនួយបាន។ ទីមួយ "មន្ត្រីទំនាក់ទំនងមួយរូប សម្រាប់ផ្តល់សេវាក្នុងការសម្របសម្រួលទំនាក់ទំនងឲ្យបានទាន់ពេលវេលា និងទៀងទាត់ជាមួយអាជ្ញាធរជាតិ អំពីបញ្ហាពាក់ព័ន្ធនឹងទោសរបស់ទណ្ឌិត រួមទាំងការរាយការណ៍អំពីការអនុវត្ត និងការប្រព្រឹត្តចំពោះទណ្ឌិត។ ម្យ៉ាងវិញទៀត ការិយាល័យរដ្ឋបាលបានចាត់តាំងមន្ត្រីទទួលបន្ទុកដាច់ដោយឡែកមួយរូបទៀត ជាមន្ត្រីទំនាក់ទំនងជាមួយគ្រប់ផ្នែកតុលាការពាក់ព័ន្ធ រួមទាំង អង្គជំនុំជម្រះ និងភាគីសម្រាប់បញ្ហាណាមួយដែលទាក់ទងនឹងការឃុំខ្លួនទណ្ឌិត"[11]។ មេធាវីការពារក្តី ខៀវ សំផន មិនបានបញ្ជាក់នៅក្នុងសេចក្តីសង្កេតរបស់មេធាវីការពារក្តី ថាតើ ពួកគេបានព្យាយាមស្វែងរកដំណោះស្រាយបញ្ហាដែលពួកគេបានកំណត់អត្តសញ្ញាណទាំងនេះ ជាមួយមន្ត្រីទាំងពីររូបនេះហើយ ឬនៅ ដែលមន្ត្រីទាំងពីរនេះមានកាតព្វកិច្ចច្បាស់លាស់ក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងការឃុំខ្លួនរបស់ ខៀវ សំផន ហើយប្រសិនបើបានទាក់ទងហើយ តើពួកគេបានឆ្លើយតបយ៉ាងដូចម្តេច។

### *ii. បណ្តឹងសើរើសាលដីកាស្ថាពរតាមវិធាន ១១២ គឺជាឧបាស្រ័យវិសាមញ្ញ ផ្អែកលើកាលៈទេសៈមិនពាក់ព័ន្ធនឹងសាលដីកា វាមិនមែនជាបណ្តឹងសាទុក្ខកម្រិតទីពីរទេ*

9. អំណះអំណាងរបស់ ខៀវ សំផន ដែលថា គាត់ត្រូវការកុំព្យូទ័រយួរដៃ និងជំនួយ ដើម្បីអាន និងស្វែងយល់សាលដីកា គឺមានទំនាក់ទំនងយ៉ាងច្បាស់លាស់ទៅនឹងទស្សនៈដែលថា ការពិនិត្យបែបនេះត្រូវបានធ្វើឡើងក្នុងគោលបំណងពិចារណាដាក់បណ្តឹងសើរើ តាមវិធាន ១១២[12]។ សហព្រះរាជអាជ្ញាទទួលស្គាល់ថា ខៀវ សំផន មានសិទ្ធិអានសាលដីកាប្រឆាំងនឹងគាត់។ ទោះជាយ៉ាងណាមិនមានបណ្តឹងសាទុក្ខណាបន្ថែមទៀតឡើយ និងហេតុដូច្នេះ មិនមានកិច្ចដំណើរការនីតិវិធីបន្ត ដែលតម្រូវឲ្យ ខៀវ សំផន វិភាគភស្តុតាងដែលបានទទួលយកនៅដំណាក់កាលជំនុំជំម្រះ និងដំណាក់កាលបណ្តឹងសាទុក្ខនោះទេ។ ឧបាស្រ័យតែមួយគត់ដែល ខៀវ សំផន មាន ដើម្បីទទួលបានសេចក្តីសម្រេចផ្សេងនោះ គឺការដាក់បណ្តឹងសើរើតាមវិធាន ១១២ នៃវិធានផ្ទៃក្នុង។ នេះគឺជាឧបាស្រ័យវិសាមញ្ញ ដែលនឹងត្រូវអនុវត្តតែក្នុងកាលៈទេសៈដ៏តិចតួចប៉ុណ្ណោះ។ វាពិតជាមិនមែនបណ្តឹងសាទុក្ខដែលចេញពីសាលដីកានោះទេ។

---

[11] ឯកសារ **F77/1/2** សេចក្តីសង្កេតរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៤។

[12] ឯកសារ **F83** សេចក្តីសង្កេតរបស់មេធាវីការពារក្តី កថាខណ្ឌ ៩។

10. ជាពិសេស បណ្ដឹងសើរើតាមវិធាន ១១២ នៃវិធានផ្ទៃក្នុង អាចសមស្របតែនៅពេលដែល៖ ភស្តុតាងថ្មីត្រូវបានរកឃើញ ដែលមិនមាននៅពេលជំនុំជម្រះ *និង* ដែលទំនងជានាំឲ្យមានសេចក្ដីសម្រេចផ្សេង នៅពេលដែលវាត្រូវបានរកឃើញជាថ្មីថា ភស្តុតាងដែលជាកត្តាកំណត់នោះគឺក្លែងក្លាយក្លែងបន្លំ ឬខុសការពិត ឬនៅពេលដែលចៅក្រមម្នាក់ប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ឬរំលោភបំពានភារកិច្ចធ្ងន់ធ្ងរនៅក្នុងរឿងក្ដីដែលពាក់ព័ន្ធនោះ[13]។ គណៈកម្មាការច្បាប់អន្តរជាតិ បានបង្ហាញទស្សនៈថា បណ្ដឹងសើរើ "មិនត្រូវរាប់បញ្ចូល [...] ការចោទប្រកាន់អំពីកំហុសក្នុងការវាយតម្លៃអង្គហេតុ ដែលបង្ហាញនៅពេលជំនុំជម្រះ ឬ កំហុសអង្គច្បាប់ ឬនីតិវិធី ដែលជាបញ្ហាសម្រាប់ដំណើរការបណ្ដឹងសាទុក្ខនោះទេ"[14]។ តុលាការមិនអចិន្ត្រៃយ៍អនុវត្តបទដ្ឋានធូរស្រាល សម្រាប់បណ្ដឹងសើរើ (ហៅថា "ការពិនិត្យឡើងវិញ" នៅតុលាការមិនអចិន្ត្រៃយ៍) ជាងបទដ្ឋានដែលអនុវត្តនៅចំពោះមុខ អ.វ.ត.ក និង តុលាការព្រហ្មទណ្ឌអន្តរជាតិ។ ប៉ុន្តែ ទោះបីជាស្ថិតក្រោមបទដ្ឋានកម្រិតទាបនោះក្ដី ចៅក្រមបានសម្រេចថា "គេមិន [...] អាចជំទាស់ទៅនឹងសេចក្ដីសម្រេចពីមុនរបស់ [...] អង្គជំនុំជម្រះថាមិនត្រឹមត្រូវ ផ្អែកលើមូលដ្ឋានដែលសេចក្ដីសម្រេចទាំងនោះបានធ្វើឡើងនោះទេ"។ ផ្ទុយទៅវិញ ពាក្យសុំឲ្យពិនិត្យឡើងវិញ អាចធ្វើទៅបាននៅពេលដែល "គេមើលឃើញថា ការសន្និដ្ឋានទាំងនោះនឹងខុសពីនេះ ប្រសិនបើអង្គហេតុថ្មីជាក់លាក់មាននៅចំពោះមុខ [...] អង្គជំនុំជម្រះ នៅពេលធ្វើសេចក្ដីសម្រេចដើមដំបូងនោះ[15]"។ ហេតុដូច្នេះ ទោះបីជាវាអាចសមស្របសម្រាប់ ខៀវ សំផន ក្នុងការទទួលបានជំនួយពីមេធាវីក្នុងការស្វែងយល់សាលដីកាប្រឆាំងនឹងគាត់ ផ្អែកលើមូលហេតុផ្សេងៗទៀតក៏ដោយ ក៏ការស្វែងយល់អំពីសាលដីកានេះ ចាំបាច់តែក្នុងគោលបំណងតាមវិធាន ១១២ ប៉ុណ្ណោះ នៅពេលដែលកាលៈទេសៈបុរេលក្ខខណ្ឌមួយ ក្នុងចំណោមកាលៈទេសៈបុរេលក្ខខណ្ឌនានាក្នុងវិធាន ១១២(១) ត្រូវបានកំណត់អត្តសញ្ញាណ។ សហព្រះរាជអាជ្ញាគូសបញ្ជាក់ថាបុរេលក្ខខណ្ឌ

[13] វិធាន ១១២(១) នៃវិធានផ្ទៃក្នុង។

[14] គណកម្មការច្បាប់អន្តរជាតិ សេចក្ដីព្រាងលក្ខខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ អមដោយសេចក្ដីអត្ថាធិប្បាយ ឆ្នាំ១៩៩៤ A/49/10, មាត្រា ៥០។ គណកម្មការច្បាប់អន្តរជាតិបង្ហាញទស្សនៈនេះ ទាក់ទងនឹងឧបាស្រ័យនៃបណ្ដឹងសើរើនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងសេចក្ដីព្រាងលក្ខខន្តិកៈរបស់ខ្លួន។ បទប្បញ្ញត្តិ អ.វ.ត.ក សម្រាប់បណ្ដឹងសើរើមានគំរូដូចគ្នានឹងបទប្បញ្ញត្តិនៃតុលាការ ICC _ វិធាន ១១២(១) ចម្លងតាមមាត្រា ៨៤(១) នៃលក្ខខន្តិកៈទីក្រុងរ៉ូមស្ទើតែទាំងស្រុង _ ដូច្នេះ ការសន្និដ្ឋាននេះគួរត្រូវបានពិចារណាថា អនុវត្តបានចំពោះការដាក់បណ្ដឹងសើរើសាលក្រមស្ថាពរនៅ អ.វ.ត.ក ផងដែរ។

[15] *រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង Barayagwiza សំណុំរឿង*លេខ ICTR-97-19-AR72, សេចក្ដីសម្រេច (សំណើរបស់រដ្ឋអាជ្ញាស្នើសុំពិនិត្យឡើងវិញ ឬពិចារណាឡើងវិញ) ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២000 យោបល់ដោយឡែករបស់ចៅក្រម Shahabudeen កថាខណ្ឌ ២។

ទាំងបីក្នុងវិធាន ១១២(១) ផ្អែកលើការលេចឡើងនូវភស្តុតាងថ្មី ឬព័ត៌មានផ្សេងទៀតដែល តាមនិយមន័យ នឹងមិនមាននៅក្នុងសាលដីកានោះទេ។

### *iii. អង្គជំនុំជម្រះតុលាការកំពូល នៅតែដំណើរការ និងជាវាទិការសមស្របសម្រាប់ ខៀវ សំផន ក្នុងការដោះស្រាយការចោទប្រកាន់លើការរំលោភសិទ្ធិរបស់គាត់*

11. ទោះបីជា ខៀវ សំផន បង្ហាញពីភាពមិនច្បាស់លាស់ចំពោះបញ្ហាថាតើ អង្គជំនុំជម្រះតុលាការកំពូលបន្តស្ថិតក្នុងទម្រង់បច្ចុប្បន្ន ឬយ៉ាងណា ឬ មានយុត្តាធិការលើលក្ខខណ្ឌនៃការឃុំខ្លួនរបស់គាត់ ឬយ៉ាងណា[16] កិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បញ្ជាក់ច្បាស់ថា អង្គជំនុំជម្រះវិសាមញ្ញនៅតែដំណើរការតាមការចាំបាច់ ដើម្បីអនុវត្តមុខងារដែលបានរៀបរាប់នៅក្នុងកិច្ចព្រមព្រៀងបន្ថែមនោះ[17]។ កិច្ចព្រមព្រៀងបន្ថែមចែងថា "អង្គជំនុំជម្រះវិសាមញ្ញត្រូវបន្ត*បំពេញ* មុខងារនានា" ដែលបង្ហាញពីស្ថានភាពបន្តធម្មនុញ្ញភាព និងភារកិច្ចរបស់អង្គជំនុំជម្រះ[18]។ កិច្ចព្រមព្រៀងបន្ថែមបញ្ជាក់ថា ម្តងម្កាល ចៅក្រមនឹង "បំពេញការងារដូចបានកំណត់ក្នុង [មាត្រា ២(១)]"[19]។ វាក៏ចែងអំពីការតែងតាំងចៅក្រមអន្តរជាតិបន្ថែម "ដើម្បីធានាថាមានចំនួនចៅក្រមអន្តរជាតិគ្រប់គ្រាន់ដើម្បីបំពេញមុខងារទៅតាម [មាត្រា ២(១)]"[20]។ បទប្បញ្ញត្តិទាំងនេះបញ្ជាក់ច្បាស់ថា ចៅក្រម និងអង្គជំនុំជម្រះនៃ អ.វ.ត.ក (ជាមួយនឹងស្ថាប័នផ្សេងទៀតរបស់តុលាការ) ត្រូវអនុវត្តមុខងារសេសសល់ ដែលមានចែងក្នុងមាត្រា ២(១) ដែលរួមបញ្ចូលទាំងបណ្តឹងសើរើសាលក្រមស្ថាពរតាមវិធាន ១១២ និងការតាមដានការប្រព្រឹត្តលើទណ្ឌិតជាប់ឃុំផងដែរ[21]។ ការយោងសំដៅលើ "អង្គជំនុំជម្រះ" នៅក្នុងវិធាន ១១២(១) សំដៅលើអង្គជំនុំជម្រះដែលចេញសាលក្រមស្ថាពរ ដែលក្នុងករណីបច្ចុប្បន្ននេះគឺអង្គជំនុំជម្រះតុលាការកំពូល។

12. សេចក្តីសម្រេចថ្មីៗនេះរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីសេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញក្នុងសំណុំរឿង ០០២ បញ្ជាក់ច្បាស់ថា អង្គជំនុំជម្រះតុលាការកំពូល នៅតែ

[16] **F83** សេចក្តីសង្កេតរបស់មេធាវីការពារក្តី កថាខណ្ឌ ១៣-១៦។

[17] កិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យស្តីពី ការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អ.វ.ត.ក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ និងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ("កិច្ចព្រមព្រៀងបន្ថែម")។

[18] កិច្ចព្រមព្រៀងបន្ថែម មាត្រា ២(១)។

[19] កិច្ចព្រមព្រៀងបន្ថែម មាត្រា ២(៥)។

[20] កិច្ចព្រមព្រៀងបន្ថែម មាត្រា ២(៦)។

[21] កិច្ចព្រមព្រៀងបន្ថែម មាត្រា ២(១)។

ដំណើរការ និងថាអង្គជំនុំជម្រះបច្ចុប្បន្ន និងទៅអនាគតនឹងបន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្តមុខងារ ដែលមានរៀបរាប់នៅក្នុងកិច្ចព្រមព្រៀងបន្ថែម[22]។ ដូច្នេះ សហព្រះរាជអាជ្ញាយល់ឃើញថា វាច្បាស់ណាស់ថា អង្គជំនុំជម្រះតុលាការកំពូល គឺជាវេទិការសមស្របសម្រាប់ការសម្រេចអំពីសិទ្ធិរបស់ ខៀវ សំផន លើបញ្ហានានាទាក់ទងនឹងការឃុំខ្លួនគាត់ (ប្រសិនបើក្រុមមេធាវីការពារក្ដី ខៀវ សំផន បានប្រើប្រាស់អស់លទ្ធភាពក្នុងការពិគ្រោះយោបល់ជាមួយអាជ្ញាធរជាតិ និងមន្ត្រីពីររូបដែលបានតែងតាំងដោយការិយាល័យរដ្ឋបាល ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងការឃុំខ្លួនគាត់ជាមុន) ឬកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន ១១២៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | [signature] |
| | **លោក Fergal GAYNOR** សហព្រះរាជអាជ្ញាអន្តរជាតិ (បម្រុង) | | [signature] |

[22] **F71/1/1/8** សេចក្ដីសម្រេចស្ដីពីសេចក្ដីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣។